គណៈកម្មាធិការ
សហប្រតិបត្តិការដើម្បីកម្ពុជា
Cooperation Committee
for Cambodia
Comité de Coopération
Pour le Cambodge

**ទស្សនវិស័យ:** ការអភិវឌ្ឍប្រកបដោយនិរន្តរភាពសម្រាប់ប្រទេសកម្ពុជា
**Vision:** Sustainable development for Cambodia

លេខ: ០២៦៣ គ.ស.ក/២០១៨

**សូមគោរពជូន**
**ឯកឧត្តម បណ្ឌិត ងី តាយី**
**រដ្ឋលេខាធិការ ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និងជាប្រធាន ក្រុមប្រឹក្សាជាតិគណនេយ្យ**

**កម្មវត្ថុ:** សំណើសុំកិច្ចអន្តរាគមន៍ក្នុងការអនុវត្តន៍ច្បាប់ស្តីពីគណនេយ្យ និងសវនកម្មសម្រាប់អង្គភាពមិនស្វែងរកប្រាក់ចំណេញ។

តបតាមកម្មវត្ថុ ខ្ញុំបាទមានកិត្តិយសសូមជម្រាបជូន **ឯកឧត្តមបណ្ឌិត** មេត្តាជ្រាបថា អង្គការគណៈកម្មាធិការសហប្រតិបត្តិការដើម្បីកម្ពុជា (គ.ស.ក) ឬភាសាអង់គ្លេសហៅថា Cooperation Committee for Cambodia (CCC) ជាអង្គការសមាជិកភាពដែលមាន ២០០ អង្គការ និងសមាគមក្នុងស្រុក និងអង្គការបរទេសជាសមាជិក និងមានអង្គការសមាជិកបណ្តាញនៃអង្គការ គ.ស.ក ប្រមាណជាង៥០០ និងអង្គការ សមាគម ជាច្រើនទៀតជាដៃគូ បាននឹងកំពុងអនុវត្តន៍នូវបទដ្ឋានមូលដ្ឋានគណនេយ្យចំនួនពីរសំខាន់ៗ គឺមូលដ្ឋានបញ្ចូលគ្នារវាងមូលដ្ឋានគណនេយ្យសាច់ប្រាក់ (the Modified Cash Basis) រឺ មូលដ្ឋានគណនេយ្យបង្គរ (the Accrual Basis) ហើយអង្គការ សមាគមមួយចំនួនតូចបានកំពុងប្រើប្រាស់បទដ្ឋានមូលដ្ឋានគណនេយ្យសាច់ប្រាក់ (the Cash Basis) សុទ្ធសាធ ដើម្បីធ្វើជាប្រព័ន្ធកត់ត្រាចំណាយ និងចំណូលរបស់ស្ថាប័ន។

ជាមួយគ្នានេះដែរ នៅចុងឆ្នាំ២០១៨ និងដើមឆ្នាំ២០១៩ គឺជារដូវកាលធ្វើសវនកម្មរបាយការណ៍ហិរញ្ញវត្ថុរបស់សមាគម និងអង្គការមិនមែនរដ្ឋាភិបាល ហើយពួកគេ បាននឹងកំពុងជួបប្រទះបញ្ហាមួយចំនួនដោយសវនករ ទាមទារឲ្យមានតែមានប្រព័ន្ធកត់ត្រាចំណាយ ចំណូល (បទដ្ឋានមូលដ្ឋានគណនេយ្យ) តាមលក្ខខណ្ឌច្បាប់ស្តីពីគណនេយ្យ និងសវនកម្ម ដែលតម្រូវឲ្យប្រើប្រាស់បទដ្ឋានមូលដ្ឋានគណនេយ្យសាច់ប្រាក់ (the Cash Basis) ជាដាច់ខាត ក្នុងខណៈពេលដែលសមាគម និងអង្គការមិនមែនរដ្ឋាភិបាលជាច្រើន មានប្រព័ន្ធកត់ត្រារបាយការណ៍ហិរញ្ញវត្ថុដូចបានរៀបរាប់ខាងលើ។ ឆ្លងតាមសិក្ខាសាលារៀនសូត្រ និងពិគ្រោះយោបល់ថ្នាក់តំបន់ និងថ្នាក់ជាតិ ដែលមានវាគ្មិនពីក្រុមប្រឹក្សាជាតិគណនេយ្យ និងអ្នកចូលរួមជាមន្ត្រី ថ្នាក់ដឹកនាំនៃសមាគម និងអង្គការមិនមែនរដ្ឋាភិបាល សរុបប្រមាណជាង៥០០នាក់ បានយល់ឃើញថា សមាគម និងអង្គការមិនមែនរដ្ឋាភិបាល អាចប្រើប្រាស់ប្រព័ន្ធកត់ត្រាចំណាយ-ចំណូល ឬហៅថាបទដ្ឋានមូលដ្ឋានគណនេយ្យ ទាំងបីប្រភេទខាងលើ ដោយគ្រាន់តែពួកគេធ្វើសេចក្តីរាយការណ៍ព័ត៌មានហិរញ្ញវត្ថុស្របទៅតាមទំរង់របាយការណ៍ដែលកំណត់។



www.ccc-cambodia.org
info@ccc-cambodia.org
T +855 (0)23 214 152
F +855 (0)23 216 009

#9-11, Street 476,
Toul Tompoung 1, Chamkamorn
P.O. Box 885, Phnom Penh,
Cambodia


Accountability គណនេយ្យភាព
GPP
25/08/2015 24/08/2018
Symbol of Trust

បញ្ហាមួយទៀតគឺ មានការស្នើសុំ និងត្អូញត្អែរពីសមាគម និងអង្គការមិនមែនរដ្ឋាភិបាលមួយចំនួនដែលបានចុះឈ្មោះតាមប្រព័ន្ធអនឡាញ (Online) ក្នុងការស្នើសុំលេខអត្តសញ្ញាណកម្មសម្រាប់អង្គភាពមិនស្វែងរកប្រាក់ចំណេញ ជាមួយគេហទំព័ររបស់ក្រុមប្រឹក្សាជាតិគណនេយ្យ ថាពួកគេកំពុងជួបបញ្ហាចុះឈ្មោះមិនទទួលបានជោគជ័យ ដោយហេតុថាគេហទំព័ររបស់ក្រុមប្រឹក្សាជាតិគណនេយ្យនៅមានភាពរអាក់រអួលផ្នែកបច្ចេកទេសក្នុងការបំពេញទម្រង់ស្នើសុំលេខអត្តសញ្ញាណកម្មតាមអនឡាញ (online) ។ ក្នុងន័យនេះ យើងខ្ញុំសូមស្នើសុំ ក្រុមប្រឹក្សាជាតិគណនេយ្យ ជួយសម្រួលពិនិត្យ ឬតេស្តសាងល្បងលើបញ្ហាបច្ចេកទេសនៃកម្មវិធី ឬប្រព័ន្ធចុះឈ្មោះដែលកំពុងដាក់អោយដំណើរការ។

សេចក្តីដូចបានជម្រាបជូនខាងលើសូមនេះ **ឯកឧត្តមបណ្ឌិត** មេត្តាធ្វើអន្តរាគមន៍ និងផ្តល់ដំណោះស្រាយចំពោះបញ្ហាសំខាន់ៗចំនួនបី(៣)រួមមាន៖ (១) សូមបង្កើនការផ្សព្វផ្សាយ កសាងសមត្ថភាព ផ្តល់ពេលវេលាសមស្រប ដល់ សមាគម និងអង្គការមិនមែនរដ្ឋាភិបាលក្នុងការអនុលោមតាមច្បាប់, (២) អនុញ្ញាតឲ្យសមាគម និងអង្គការមិនមែនរដ្ឋាភិបាល បន្តប្រើប្រាស់ប្រព័ន្ធកត់ត្រាចំណាយ ចំណូលរបស់អង្គភាព ឬបទដ្ឋានមូលដ្ឋានគណនេយ្យ ដែលពួកគេកំពុងប្រើប្រាស់ជាធរមាន ឬអនុវត្តកន្លងមក។ (៣) ស្នើជួយសម្រួលក្នុងការត្រួតពិនិត្យលក្ខខណៈបច្ចេកទេសនៃប្រព័ន្ធចុះឈ្មោះយកលេខអត្តសញ្ញាណកម្មតាមប្រព័ន្ធអនឡាញ (Online) ដែលត្រូវបានដាក់ឲ្យដំណើរការដោយក្រុមប្រឹក្សាជាតិគណនេយ្យឲ្យមានលក្ខណៈប្រក្រតី និងស្វែងរកដំណោះស្រាយបញ្ហាផ្សេងៗដែលពាក់ព័ន្ធនឹងអង្គការសង្គមស៊ីវិលដោយក្តីអនុគ្រោះ។

សូម **ឯកឧត្តមបណ្ឌិត** មានសុខភាពល្អ បរិបូរណ៍ និងសូមទទួលនូវការគោរពដ៏ខ្ពង់ខ្ពស់អំពីខ្ញុំ។

រាជធានីភ្នំពេញថ្ងៃ ពុធ ០៤ រោច ខែ មិគសិរ ឆ្នាំ ច សំរិទ្ធិស័ក ព.ស ២៥៦២

ត្រូវនឹងថ្ងៃទី ២៦ ខែ ធ្នូ ឆ្នាំ២០១៨

**នាយកប្រតិបត្តិ**

**សឿន សារឿន**

*សូមទំនាក់ទំនងនូវការឆ្លើយតបតាមរយៈ*

*លោក យឿង សុធារ៉ា ទូរស័ព្ទលេខ ០៧០៤០០ ១៣១/*

*០៩៧៩ ៦០៩០៩០*

*ឬ Email: sotheara.yoeurng@ccc-cambodia.org*